ទេសអាល្លឺម៉ាញ (Allemagne) បានផ្តល់ចំពោះមនុស្សជាតិ នូវមេរៀនមួយជាដំណំ ។

ការអ្វីដែលគេស្មានថាពុំអាចកើតមានឡើងសោះ ជួនកាលក៏អាចកើតមានឡើងបានដែរ ហើយការនេះក៏ស្រេចទៅលើទេសៈកាលៈតាមកាលសម័យផង ស្រេចទៅលើឆន្ទៈនៃអ្នកនយោបាយជាតិនោះផង ។ ប្រទេសអាល្លឺម៉ាញ បានអនុវត្តនូវទ្រឹស្តីនយោបាយរបស់អ្នកដឹកនាំឈ្មោះហ៊ីត្លែរ(Hitler តាមការឱ្យប្រជាជាតិអាល្លឺម៉ង់ មានសិទ្ធិរស់នៅលើដែនដីមួយធំ ហើយដែលគេចាត់ដែនដីនេះថា ជាអាយុជីវិតរបស់គេ(Théorie de l'Espace Vital) ។

ចលនានៃការពង្រីកទឹកដីនេះ ជនជាតិអាល្លឺ-ម៉ង់គេបានធ្វើឡើង ដោយអាងទៅលើគំនិតខុសមួយដែលថែងថា ប្រជាជាតិអាល្លឺម៉ង់ ជាប្រជាជាតិខ្លាំងពូកែខ្ពង់ខ្ពស់ជាងគេឯង ទៅលើជនជាតិដទៃទៀត មានជនជាតិស្លាវ (Slaves)និងឡាតាំង ( Latins ) ទាំងឡាយដែលរស់នៅ



ក្នុងទ្វីបអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិចជាដើមនេះ ។ បើប្រសិនជាជនជាតិអាល្លឺម៉ង់ ជាជាតិខ្លាំងពូកែយ៉ាងនេះ ហើយ ធម្មជាតិត្រូវតែប្រគល់ ទៅឱ្យប្រជាជាតិអាល្លឺម៉ង់ នូវដែនដីមួយធំល្មម ដាប់ឱ្យប្រជាជាតិ រស់ដោយស្រួល ( Lebensraum ) ! ។ កត្តាជាសារវន្តមួយទៀត គឺការចំរើនលូតលាស់នៃឧស្សាហ៍ និងមហិទ្ធិរិទ្ធិ នៃឧស្សាហកម្ម និងសេដ្ឋកិច្ចទូទៅ នៃប្រទេសអាល្លឺម៉ាញនេះឯង,ហើយជាមួយនឹងកម្លាំងសេដ្ឋកិច្ចនេះ , កម្លាំងយោធាគួរឱ្យព្រឺខ្លាច នៃប្រទេសនេះទៀតផង ដែលជំរុញឱ្យអ្នកដឹកនាំ នយោបាយអាល្លឺម៉ង់សម័យណាស៊ីស្ត អនុវត្តដោយគ្មាន ខ្លាចរអែង នូវទ្រឹស្តី ពង្រីកទឹកដីនិយម ដ៏ចង្រៃអមង្គលនេះ ។ ដើម្បីសម្រេចនូវគោលបំណងអាក្រក់នេះ អ្នកនយោបាយ អាល្លឺម៉ង់ ចាប់ផ្តើមប្រកាសតាមការតម្រូវឱ្យវិលចូល មកក្នុងមហាគ្រួសារអាល្លឺម៉ង់ នូវដែនដីបរទេស នាអឺរ៉ុបខាងកណ្តាល និងខាងកើតទាំងឡាយណា ដែលមានជនជាតិភាគតិចអាល្លឺ

មិត្តរបស់គេ ហើយដែលនិយាយភាសាអាល្លឺម៉ង់ផង ។ គឺក្នុងគំនិតដូចទៅនឹងគំនិតនេះឯង ដែលអ្នកនយោបាយអាល្លឺម៉ង់បំបះបោរបណ្ដុះបង្កើតជាចលនា ឬគណៈបក្សអាល្លឺម៉ង់ណាស៊ីក្នុងចំណោមពួកអាល្លឺម៉ង់ទាំងឡាយ ដែលនៅឯបរទេស គឺក្នុងប្រទេសជិតខាងនេះតែម្ដង ។ កាលបើមានជាអង្គការទាមទារស្វយ័ត (Mouvements autonomistes) ឬចលនាទាមទារការផ្ដាច់ចេញ (Mouvements séparatistes) ដែលមានសញ្ជាតិអាល្លឺម៉ង់ ហើយ, ចលនាទាំងនេះ តែងបានអំពាវនាវឲ្យមាតុប្រទេសអាល្លឺម៉ង់ ជួយជ្រោមជ្រែងអន្តរាគមខ្លួនដោយចុះអន្តរាគមន៍ផ្លូវសឹក នយោបាយឬទូតជាដើម ។

គឺទេសៈកាលៈនេះឯងហើយ ដែលបណ្ដាលឲ្យឲ្យអ្នកដឹកនាំអាល្លឺម៉ង់ សម្រេចនូវបំណងដ៏អាក្រក់ នៃទ្រឹស្ដីរបស់ខ្លួន ។ ក្នុងន័យនេះ ប្រទេសអូទ្រីសទាំងមូល (l'Autriche) ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកណាស៊ីស្ដនិយមក្នុងឆ្នាំ១៩៣៨ ។ ដែនដីភាគខាងលិចនៃប្រទេសឆេកូស្លូវ៉ា



គី គឺតំបន់ស៊ុយដែត (La région des Sudètes) ដែលមានជនជាតិអាល្លឺម៉ង់ រស់នៅពីមុនចំនួនជាង៣លាននាក់ ត្រូវក្លាយទៅជាអាណាខេត្តអាល្លឺម៉ង់ ។ ក្រោយមកគឺប្រទេសឆេកូស្លូវ៉ាគីទាំងមូលទៀត ក៏ត្រូវក្លាយទៅជាដែនដីអាណាព្យាបាលអាល្លឺម៉ង់ទៀត ។ ល ។

ឧទាហរណ៍នេះ មានលក្ខណៈជាក់ស្ដែងណាស់ហើយ ។ តើយើងអាចស្មានថា តើព្រឹត្តិការណ៍ដូចទៅនឹងនេះ នឹងអាចកើតឡើងជាថ្មីទៀត ឬ ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ។ ជាការពិតណាស់ ជួនកាលប្រវត្តិសាស្ត្រវិលចុះវិលឡើង ត្រឡប់មកក្រោយវិញក៏មាន .... ។ ការដែលយើងគ្រាន់តែក្រឡេកមើលទៅជនជាតិអាស៊ីកណ្ដាល (Les peuples de l'Asie Centrale) ដែលសព្វថ្ងៃនេះស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងនៃក្រុងម៉ូស្គូ ( Moscou ) ចុះណ្ហះយើងក៏អាចមានគំនិតខ្លះដែរ ហើយអំពើហេតុនៃកម្លាំងសេដ្ឋកិច្ចនយោបាយនិងយោធានៃមហាប្រទេសមួយទៅលើប្រជាជាតិតូចតាច ។

ចុះនៅបច្ចុប្បន្ននេះវិញ តើឧទាហរណ៍ "អាល្ហ៊ីម៉ង់" អាចមានឡើងជាសាថ្មីទេ នៅក្នុងតំបន់យើងនេះ ? ការនេះស្រេចទៅលើប្រវត្តិសាស្ត្រប្រាប់យើងក្នុងអនាគតចុះ . . . យើងគ្រាន់តែសូមផ្តល់ជូន វិភាគនៃស្ថានការណ៍នយោបាយនិងសេដ្ឋកិច្ចក្នុងក្រោយបច្ចុប្បន្នតែប៉ុណ្ណោះ ដើម្បីជាការពិចារណាតទៅ ៖

ប្រជាជាតិប្រជារាស្ត្រវៀតណាម ជាប្រជាជាតិមួយដែលគេគប់រាប់ទុក ដោយគ្មានលាក់លៀមថា មានថាមពល (dynamisme) មានគុណសម្បត្តិខាងផ្លូវបញ្ញា ( les qualités intellectuelles) គ្រប់គ្រាន់ ។ល។ សេដ្ឋកិច្ចប្រទេសវៀតណាមក្រោយសង្គ្រាម ជាសេដ្ឋកិច្ចដែលនឹងមានកម្លាំងក្លៀវក្លាស្របជាមួយនឹងកំរិតជំនាញខ្ពស់ខាងការសិក្សាវិទ្យាសាស្ត្រ និងបច្ចេក-ទេសនៃជនជាតិនេះ ។ ម្យ៉ាងទៀត ខាងផ្លូវនយោបាយ, ប្រទេសវៀតណាមនឹងមានកងទ័ពដ៏ខ្លាំងពូកែ ក្នុងចំណោមប្រជាជាតិទាំងឡាយ នៅក្រោយបច្ចុប្បន្ននិងក្នុងអាស៊ីអាគ្នេយ៍នេះ ។ តែប៉ុន្តែហេតុការណ៍មួយទៀត ដែល



យើងមានការបារម្ភតែនៅពេលនោះ គឺ ជាការដែលមានការណ៍និងមានជនជាតិយួន (les colonies vietnamiennes) យ៉ាងសំខាន់ក្នុងប្រទេសជិតខាងទាំងឡាយ :

នៅប្រទេសកម្ពុជា - ជាង ៤០០ ០០០ នាក់[១]

ប្រទេសលាវ ជាង៤០.០០០ នាក់ ( បើគិតរួមនិងទាហានវៀតណាមខាងជើង )

ប្រទេសសៀម – ជាង ៤០.០០០នាក់ ។

នៅប្រទេសកម្ពុជាយើង គ្រាន់តែចំនួននៃជនបរទេសយួននេះធ្វើឲ្យយើងមានការបារម្ភនោះគ្រប់ពេលណាស់ទៅហើយ ។ ហើយប្រសិនបើការលួចចូលមកកាន់តែច្រើនបន្តទៅទៀត គេពិបាកនឹងសន្និដ្ឋានណាស់ចំពោះផលវិបាក ខាងផ្លូវសេដ្ឋកិច្ចក៏ដូចជាខាងផ្លូវនយោបាយដែលប្រទេសយើង ត្រូវទទួលរងគ្រោះ ។ ជាពិសេសណាស់ទៅទៀត ជនជាតិយួនទាំងនេះ

(១) ក្រោយថ្ងៃ ១៨ មីនា ១៩៧០ , ជនជាតិយួនជាង ១០០.០០០ នាក់ ត្រឡប់ទៅវៀតណាមខាងត្បូងវិញ ។

ពុំអាចនឹងរលាយចូលទៅក្នុងសង្គមជាតិនានា ទាំងនោះទៀត នោះនៅថែរក្សាប្រពៃណី ទំនៀមទម្លាប់ខ្លួន នឹងចំណងទាក់ទងចិត្តនយោបាយជាមួយនឹងមាតុប្រទេសដើមកំណើត ។ គឺក្នុងគំនិតនេះហើយ ដែលគេត្រូវចាត់ទុកជនជាតិយួនជាជាគ្រោះថ្នាក់យ៉ាងធំ មួយខាងផ្នែកនយោបាយ ។

ការដែលប្រទេសវៀតណាម នឹងត្រូវលូត លាស់ផុះផុលក្រោយសម័យសង្គ្រាមនេះទៅ នឹងអាចធ្វើឱ្យចំណងផ្ចិតខាងផ្នែកនយោបាយនៃជនជាតិយួនទាំងនេះ រឹតតែមានលក្ខណៈម៉ាំទាំទាំឡើងជាពុំខាន ។ ឯចំពោះបញ្ហាជនជាតិចិនក្នុងប្រទេសយើង មានលក្ខណៈផ្សេង ដោយសារស្ថានភាពភូមិសាស្ត្រនយោបាយនៃប្រទេសយើង ( La situation géo-politique ) នឹងដោយសារជនជាតិចិនទាំងនោះ យូរឆ្នាំមកហើយ អាចជ្រួតជ្រាបរលាយចូលនឹងសង្គមជាតិយើងបន្តិចម្តងៗ ។ ហេតុដូច្នេះហើយបានជាយើង អាចអះអាងដោយគ្មានវែង ថាមិនជាគ្រោះថ្នាក់ ដល់អាយុជីវិតប្រជាជាតិខ្មែរយើង ក្នុង



អនាគតខាងមុខ គឺការលូតលាស់ផុះផុលជាថ្មីឡើងវិញ នៃប្រជាជាតិវៀតណាមនេះឯង ( la renaissance nationale vietnamienne ) ហើយជាបឋម, ក្នុងបច្ចុប្បន្នកាល ក៏ដូចក្នុងអនាគតកាលជិតៗនេះ, សន្ធនៃសេដ្ឋកិច្ច នឹងការឃោសនាផ្សព្វផ្សាយនៃមនោគមវិជ្ជាបដិវត្តនេះតែម្តង ។

x

x x

## តើយើងត្រូវធ្វើដូចម្ដេច ?

ការដែលយើងលើកយកគ្រោះថ្នាក់ដ៏ធំធេងនេះមកពិចារ-ណាឲ្យយល់ច្បាស់ដល់សម្បជញ្ញៈ នៃយើងគ្រប់គ្នាយ៉ាង ដូច្នេះ មិនខានបានសេចក្ដីថា យើងចាត់ប្រជារាស្ត្រយៀកណាម ជាសត្រូវតំណពូជ អស់មួយជីវិតជាតិយើងឡើយ (Ennemi héréditaire) ។ ចំណែកយើងវិញក៏ដូច្នោះដែរ យើងមិនឲ្យប្រជារាស្ត្រយួនដដែលនេះចាត់យើងទុកជាសត្រូវអស់មួយជីវិតដូចគ្នាដែរ ។ អតីតកាលគឺអតីតកាល យើងមិនត្រូវប្រឆាំងអតីតកាល ជាមួយនឹងបច្ចុប្បន្នកាលឬអនាគតកាលនោះឡើយ ។ ខ្លួនតែយើងគឺដូចជាខ្លួនតែជនជាតិ មានការប្រមាថគុណលោកដែរ យើងជៀសទៅរកការកសាង អនាគតមួយដែលភ្លឺស្វាង



ដែលល្អប្រពៃ ដោយពឹងផ្អែកទៅលើការយោគយល់គ្នាទៅវិញទៅមករវាងជាតិនិងជាតិ ។ ការតាំងនេះនឹងត្រូវសម្រេចឡើងដោយយោងទៅតាមមេរៀនប្រវត្តិសាស្ត្រ ដែលយើងមិនចង់ឲ្យប្រវត្តិសាស្ត្រនេះ វិលថយក្រោយនោះឡើយ ។ យើងហាក់ដូចជាបានទទួលការកក់ក្ដៅច្រើនណាស់ ពីសំណាក់អ្នកនយោបាយ ប្រទេសយួនសម័យនេះ ដោយគេបានសន្យាថានឹងមិនធ្វើ « អុកឡុក » ដល់ប្រទេសយើងឡើយ[១] គេនឹងគោរពទទួលស្គាល់អធិបតេយ្យភាពនិងបូរណភាពទឹកដីយើង ។ យើងក៏យល់ដែរនូវសន្ដានចិត្តនៃអ្នកដឹកនាំយើងនេះ ។ តែគួរឲ្យយើងយល់ថានេះជា បច្ចុប្បន្នកាល ចុះដល់ អនាគតកាលយូរទៅ ? តើយុវជនឬប្រជារាស្ត្រយួននេះ នៅតែរក្សានូវសេចក្ដីគោរពនិងការទទួលស្គាល់នេះ តទៅទៀត ? តើយុវជនឬប្រជារាស្ត្រយួននេះ នៅតែរក្សានូវសេចក្ដីគោរព

---

១ – អត្ថបទនេះសរសេរមុនថ្ងៃ១៨មីនា១៩៧០

នឹងការទទួលស្គាល់នេះកើតទៅទៀតឬ? សម័យមួយខុសសម័យមួយទៀត ហើយការដោះស្រាយបញ្ហាក៏សំរេចទៅលើការរិះគន់ចំពោះវិវេក គឺប៉ុន្តែជាការគិតគណនារបស់បុគ្គលណាជាអ្នករិះគន់ជាតិយួនទាំងឡាយ នេះមានសណ្ដានចិត្តល្អមួយស្ដេចស្អាតគ្នី ចំពោះយើង ក៏អ្នកទាំងនេះពុំគងកាត់ផ្ដេសផ្ដាស់ មិនថ្វីព្រោះថ្នាក់នេះពេលចំពោះមាតុប្រទេសយើងទាបនៅឡើយ ព្រោះនេះជាច្បាប់ធម្មជាតិ ជាលទ្ធផលនៃការវិវត្តន៍អារ្យធម៌ពីរ ដែលមានតម្លៃមិនស្មើគ្នា ( Ce serait l'aboutissement logique d'un long processus d'évolution de deux civilisations voisines de valeur inégale).

ហេតុដូច្នេះ ប្រសិនបើគ្រោះថ្នាក់នេះមានភាពជាក់ស្ដែងហើយដែលអាចក្លាយទៅជាការពិតមកហើយ ដើម្បីការពារអាយុកាលជាតិយើង យើងត្រូវតែយកបញ្ហានេះ មកបង្កើតឱ្យទាល់តែស្មារតីនិងគំនិតសម្បជញ្ញៈនៃប្រជាជាតិយើង ។ គារួមដែលរីកសុសវិសាលឯណាក៏ពុំអាចធ្វើឲ្យគោលបំណងមនុស្ស



សម្រេចជោគជ័យបានឡើយ ដើម្បីមនុស្សដែលកាន់អំណាច នៈខ្វះ សម្បជញ្ញៈ គ្រប់គ្រាន់ ចំពោះគ្រោះថ្នាក់ដែលគាបប្រល័យជីវិតខ្លួនផងនិងចំពោះកាតព្វកិច្ច ជាសារវន្តរបស់ខ្លួនផងហើយនោះ ។ ដូច្នេះហើយ ចំពោះប្រជាជាតិយើង អ្វីៗដែលសក្តិសិទ្ធិ បំផុតគាបជួយយើងឲ្យផុតពីមហន្តរាយបានគឺ«សម្បជញ្ញៈជាតិ»នេះឯងហើយ (la conscience nationale) ។ មានសម្បជញ្ញៈជាតិ គឺស្គាល់តម្លៃពិសេសវិសាលនៃជាតិខាងផ្លូវវប្បធម៌ក៏ដូចជាខាងផ្លូវសង្គម ( les valeurs socio-culturelles ) ។ ប៉ុន្តែទៀតមានសម្បជញ្ញៈជាតិ មិនគ្រាន់តែត្រឹមតែការស្នេហាជាតិ (le patriotisme) ប៉ុណ្ណោះទេ តែមានទាំងត្រឹមតែលទ្ធិជាតិនិយម ( le nationalisme ) នេះទៀត ។

លទ្ធិជាតិនិយមខាងផ្លូវនយោបាយ និងផ្លូវសេដ្ឋកិច្ចជាអាវុធនៃការតស៊ូដើម្បីជីវិតនៃប្រជាជាតិយើង ( le nationalisme politique et économique constitue l'unique arme de notre suivie en tant que nation dans cette partie du monde )

លទ្ធិ ជាតិនិយមជាទ្រឹស្ដី នយោបាយ មិនមែនគ្រាន់តែ

ក្នុងសេចក្ដីថា ការស្នេហាជាតិ ដែលគ្រាន់តែជាមនោសញ្ចេតនាមួយ ក្នុងចំណោមមនោសញ្ចេតនាទាំងឡាយ នៃមនុស្សម្នាក់ៗឡើយ ។ លទ្ធិជាតិនិយម ជាលទ្ធិដែលដាក់ទៅលើការលើកតម្លៃខ្ពង់ខ្ពស់នៃលក្ខណជាតិ នៃមនោគមវិជ្ជាជាតិ និងអ្វីៗទាំងឡាយដែលចាក់ឫសចំពោះប្រជាជាតិ ។ ទាំងអស់នេះគឺធ្វើឱ្យសម្រេចបាន ឧត្ដមគតិដ៏ខ្ពង់ខ្ពស់របស់ជាតិដូចជាការ លូតលាស់ការរីកចម្រើននៃកម្រិតរបស់ជាតិ ទាំងផ្នែកនយោបាយដូចជាខាងផ្នែកសេដ្ឋកិច្ច យោធាផ្សេងៗទៀតដែរ ។

គឺក្នុងទស្សនគតិនេះហើយដែលភារកិច្ចចម្បងរបស់យើង គឺការពង្រឹងនៃលទ្ធិជាតិនិយមរបស់យើង (Renforcer notre nationalisme) ធ្វើឱ្យលទ្ធិនេះមានគ្រឹះរឹងមាំ (Fondements solides) អាចក្លាយទៅជាមនោគមវិជ្ជាជាតិប្រកបដោយប្រសិទ្ធិភាពជាក់ស្ដែង ។ គឺមិននិយាយឲ្យទទេ គឺធ្វើឱ្យពាក្យ « ជាតិនិយម » មានន័យពេញលេញ ។ ម្យ៉ាងទៀតលទ្ធិនេះអាចលូតលាស់ទៀតទៅមុខបានគឺអាស្រ័យទៅលើការលូតលាស់ លទ្ធិប្រ



ជាធិបតេយ្យ (la démocratie) ដែលអនុញ្ញាតឲ្យប្រជារាស្ត្រអាចចូលរួមជាក់ស្ដែងក្នុងកិច្ចការរដ្ឋ ( la participation réelle et profonde du peuple dans les affaires de l'Etat ) ហើយអាស្រ័យទៅលើការផ្ដល់ផលនៃយុត្តិធម៌សង្គម(la justice sociale) ជាក់ស្ដែង ។ បើកត្តាជាសារវន្តទាំងពីរនេះខ្វះ ពាក្យជាតិនិយម ឬស្រឡាញ់ជាតិគ្រាន់តែជាស្លាកបែក តែប៉ុណ្ណោះ ពុំអាចយកជាផ្លែផ្កាអ្វីបានឡើយ ។

កត្តា « មនុស្ស » (le facteur humain) ជាកត្តាចំបំផុតក្នុងកិច្ចការកសាងជាតិ ដោយតាមសេចក្ដីចំរើនដល់កំរិតខ្ពង់ខ្ពស់នៃអារ្យធម៌ជាតិ ។

កាលបើកត្តាមនុស្ស មានសភាពថ្លៃថ្លាហើយ ការស្ថាបនាសេដ្ឋកិច្ចជាតិ ជាកាតព្វកិច្ច ចុងក្រោយបង្អស់ ។ ធ្វើប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសលូតលាស់ មានកម្លាំងសេដ្ឋកិច្ចគ្រប់គ្រាន់អាចឈរមុខទប់ទល់នឹងកម្លាំង ផ្សព្វផ្សាយនៃសេដ្ឋកិច្ចប្រទេសជិតខាងយើង នេះហើយដែលជាសេចក្ដី

ត្រូវពុំទាន់ក្រោយនៃប្រជាជាតិយើង ។ គេនិយាយថា សេដ្ឋកិច្ចដឹកនាំនយោបាយ (L 'économie dirige la politique) ។ ហើយគេនិយាយទៀតថា បើសេដ្ឋកិច្ចយើងខ្សោយ ហើយពុំអាចទទួលសម្រេចបានទេ ឯករាជ្យនយោបាយ ក៏គ្មានឡើយ (L ' indépendance politique) ។ បានសេចក្តីថា បើសេដ្ឋកិច្ចយើងខ្សោយ « ពាក្យឯករាជ្យនយោបាយ » នេះ គឺគ្រាន់តែពាក្យទទេ គ្មានសារសំខាន់អ្វីសោះ ។ យើងពុំអាចទៅឡើយដល់ទៅទទួលសម្រេចឲ្យមាន « ឯករាជ្យសេដ្ឋកិច្ច (L' indépendance économique) ពេញលេញពិតប្រាកដនេះគ្រាន់តែពាក្យស្លោកតែប៉ុណ្ណោះ ។ សម័យនេះពុំមែនសម័យ ដែលរស់នៅពឹងផ្អែកទៅលើខ្លួនឯងទាំងស្រុង (L' autarcie) បំបាត់ការទាក់ទងនឹងផ្សារសេដ្ឋកិច្ចជាមួយបរទេសទេ . . . ។ មានតែប្រទេសណាមួយ ឬ តិចប៉ុណ្ណោះក្នុងលោកនេះទេ ដែលអាចសម្រេចបានឯករាជ្យសេដ្ឋកិច្ចនេះបាន ដោយគ្មានទៅលើការ



ទ្រព្យធនធានធម្មជាតិ ដែលធម្មជាតិលោក បានប្រទានមកឲ្យប្រទេសទាំងនេះ ។ ចុះចំពោះប្រទេសយើង ដែលគ្មានធនធានធម្មជាតិអ្វីប៉ុន្មានក្រៅពី ដីល្បប់ជន្លេនមេគង្គ ប្រទេសរាបទាប ដីជាតិនិងទឹកដ៏បរិបូណ៌ ធនធាននិង កំដៅព្រះអាទិត្យ គឺយើង មានតែ ធនធានទាំង ៣ ប៉ុណ្ណោះសោះ ( ដី ទឹក កំដៅ ) ។ ហេតុយ៉ាងនេះហើយបានជា មូលដ្ឋាននៃសេដ្ឋកិច្ចជាតិយើង គឺកសិកម្មនេះឯង ។

យើងមានធនធាន ៣ ហើយ ខ្វះតែមួយទៀតប៉ុណ្ណោះ ដើម្បីសម្រេចនូវការលូតលាស់បានគឺការអប់រំកសិករយើងទៅតាមបច្ចេកទេស និងវិទ្យាសាស្ត្រទំនើប (la formation technique des agriculteurs ) ប្រសិនបើកសិកម្មយើងលូតលាស់ពេញទំហឹងហើយ ប្រទេសនឹងអាចក្លាយទៅជា « កំពូល » ក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ( le Cambobge serait « roi » de l ' Asie du Sud-Est ) ។ តើបានក្នុងតំបន់នេះ

ឬ ដែលជាមូលដ្ឋានជីវិតសេសវិលាល ទ្រទ្រង់ត្រូវលទ្ធិជាតិនិ យម សេដ្ឋកិច្ចរបស់ផ្ទៃខ្លួនយើង ។ យើងមានគ្រប់គ្រាន់ ហើយ មូលដ្ឋានទាំងនេះយើងនោះទូរតែគេខ្ទះ ប្រៀបបាន នឹង ដែក ។ ធ្នូការពេទ្យជាប៉ត្តទាំងស្រុង តែប៉ុណ្ណោះទៀតនៃដែល សេដ្ឋកិច្ចកសិកម្ម យើងនឹងត្រូវចាប់ផ្ដើមទៅមុខ ។ ១០ ឬ ២០ ឆ្នាំទៀត នយោបាយនេះ ប្រាកដជាឲ្យផលជាក់ស្តែងជាពិត ប្រាកដ ។

ប៉ុន្តែទៀត ៣០ឆ្នាំទៀតបណ្ដាជនយើង កើនដល់ទៅ ១៩លាននាក់ ប្រទេសយើងនឹងក្លាយទៅជាប្រទេសធំសម្បូរ សប្បាយមួយ ជាមហាប្រទេសមួយក្នុងតំបន់អាស៊ី តែក គង់ក្បួនមិនលែងឡើយ ។

ពេលនោះហើយ ដែលប្រជាជាតិយើងឈប់មានកៀប អោនថយជាដើម (Complexe d'infériorité) មានមុខ មាត់ជាប្រទេសមួយ ដែលមានជ័យជំនះទៅលើការតស៊ូក់ ឡាយ បានរើបម្រះចេញពីនឹងនៃប្រវត្តិសាស្ត្រ ក្រោយ



សម័យមហានគរ ( Ce sera la libération définitive de notre peuple de tant de siècles de décadence et d'écrasement physique et moral ) ។

ធ្វើយ៉ាងនេះ គឺប្រាកដជាយើងប្រគល់ទៅឲ្យប្រជាជាតិ យើងវិញនូវសេចក្តីក្លាហាន ថាមពល និងសេចក្តីថ្លៃថ្នូរដែល បាត់បង់អស់រយៈពេលជាង៦សតវត្សរ៍មកហើយ ។

X

X X

# សេចក្ដីបញ្ចប់

នៅក្នុងពិភពមួយដែលកម្លាំងសេដ្ឋកិច្ច ប្រែក្លាយទៅជា កម្លាំងលើសលប់ក្នុងការទ្រទ្រង់នូវការគង់វង្សជីវិត ( la survie ) ជាតិ, ហើយម៉្យាងទៀតនៅក្នុងភូមិភាគនេះ ដែលសភាពវិការរំភើបខ្លះស្ថានភាពជាអចិន្ត្រៃយ៍ ធ្វើឲ្យយើងពិបាកប្រមើលនូវអនាគតកាល ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពភូមិសាស្ត្រនិងនយោបាយមួយ ដែលមានលក្ខណៈស្មុគស្មាញ គេប្រផ្នូលមិនបានឡើយ ។ ស្ថានភាពនេះ ពិតជាគ្រោះថ្នាក់មួយ ដែលគំរាមកំហែងប្រទេសយើងរាល់ជំហាន នៃការវិវត្តន៍ នៃប្រទេស ។ ដើម្បីនឹងការពារមាតុប្រទេសប្រឆាំងនឹងគ្រោះថ្នាក់នេះ យើងត្រូវតែប្រមូល - នូវកម្លាំងចិត្តកម្លាំងកាយ ដើម្បីស្ថាបនាប្រទេសកម្ពុជាឲ្យក្លាយទៅជា ប្រទេស



ទេសមួយល្អណាស់ មានកម្លាំងសេដ្ឋកិច្ចគ្រប់គ្រាន់ តាមទប់ទល់នឹងការផ្សព្វផ្សាយ នៃកម្លាំងសេដ្ឋកិច្ចរបស់ប្រទេសជិតខាង ដែលសុទ្ធសឹងតែជាប្រទេសធំ ៗ មានកម្លាំងសេដ្ឋកិច្ចនិងនយោបាយគួរឲ្យយើងមានការព្រួយបារម្ភ ។

ការគង់វង្សជីវិត នៃប្រជាជាតិយើង ក្នុងស្ថានភាពដ៏លំបាកនេះកាស្រេចទាំងស្រុងទៅលើមូលដ្ឋានដែលមានលក្ខណៈប្រាកដនិយម ហើយទាំងរឹងប៉ឹងទៀតផង ។ ឯមូលដ្ឋាននោះ យើងរំលឹកម្ដងទៀតចុះ គឺគ្មានអ្វីក្រៅអំពីធនធានកសិ-កម្ម ឡើយ ។ កសិកម្មយើងល្អណាស់ បានសេចក្ដីថា សេដ្ឋកិច្ចជាតិយើងល្អណាស់ បានសេចក្ដីទៀតថា យើងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីប្រយុទ្ធប្រឆាំង នឹង ការសង្កត់សង្កិនខាងផ្លូវសេដ្ឋកិច្ចអំពីសំណាក់ នៃចក្រពត្តិនិយម និង អាណានិគមសម័យថ្មី និងអំពីសំណាក់នៃអ្នកជិតខាងយើង ។

យើងសូមដកស្រង់ពាក្យបណ្ឌិតនេរូ (Nehru) ដើម្បីបញ្ចប់អត្ថបទនេះ ៖

# ដំណើរឆ្ពោះទៅទិសខាងលិច (១)

ក្នុងលេខក្រោយបង្អស់នៃទស្សនាវដ្តី ( Etude Cambodgienne) ដែលបោះពុម្ពផ្សាយដោយក្រសួងឃោសនាការជាតិ, លោក ឆាល ម៉ៃយ៉េរ (Charles Meyer) ក្នុងចំណោម ដែលលោកជាម្ចាស់សរសេរក្នុងក្របខ័ណ្ឌ នៃការពាក់ព័ន្ធ ខ្មែរ វៀតណាម ជាអាទិ៍ដូចតទៅនេះ : «វត្តមាននៃជនជាតិយួន នៅលើទឹកដីខ្មែរជាគ្រោះថ្នាក់ធំដ៏ធ្ងន់នយោបាយហើយ

---

(១) អត្ថបទនេះបានចុះផ្សាយក្នុងសារព័ត៌មាន «ឯករាជ្យ» ពីថ្ងៃ ២០ ខែ ១ ២៨ ១៩៧៤ — ពី ៨ ខែមុន សង្គ្រាមកើតឡើងក្នុងប្រទេសយើង ។

ខ. ឃ.

ផលវិបាកនៃហេតុការណ៍នេះបានលេចធ្លោ ឲ្យឃើញរួចមកហើយនៅតាមតំបន់ខ្លះៗ ។ គេបានសង្កេតឃើញថាពួកអ្នកធ្វើការឃោសនាយួនមានសកម្មភាពយ៉ាងសំខាន់ នៅតាមភូមិជនបទខ្មែរនានា ហើយថែមទាំងបាន ណែនាំវិធីដឹកនាំដល់ពួកបះបោរដែលប្រកាន់មនោគមវិជ្ជា បែបយួននេះទៀតផង....» ។ ក្រោយមកទៀត អ្នកនិពន្ធដដែលនេះ បានសរសេរទៀតថា ៖ «លក្ខណៈដ៏គួរឲ្យព្រួយទៀត នៃបញ្ហាខ្មែរ–យួន គឺការមកតាំងនៅដោយស្ងៀមស្ងាត់ នៃជនជាតិយួននៅលើទឹកដីនៃកម្ពុជា (L'implantation pacifique des émigrés Vietnamiens en territoire Khmer) »

«គ្រួសារកសិករ ដោយសារការទម្លាក់គ្រាប់បែកនៃយុទ្ធនាការអាមេរិកាំង បង្ខំឲ្យគេចាកចោលលំនៅកំណើតរបស់ខ្លួន, បានមកស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ។ មួយភាគធំនៃអ្នកតាំងទីលំនៅនេះ បានទិញទឹកដីតាំង នៅក្រោយការបញ្ចប់សង្គ្រាមទៀត ហើយការដែលគួរប្រហាក់ប្រហែល



មួយទៀត គឺជាទីដែលមានជនជាតិយួនខ្លះ ដែលធ្លាប់បានត្រូវជាមួយនឹងអាមេរិកាំង និងភ្នាក់ងារនៃក្រុងព្រៃនគរ កាលសង្គ្រាមបញ្ចប់ហើយ នឹងចូលកាត់ព្រំដែនមកជ្រកនៅលើដែនដីខ្មែរទៀត ..... ហើយការតាំងទីនេះនឹងក្លាយជាបង្កើតឲ្យមានតួសេចក្តីព្រួយបារម្ភមួយយ៉ាងធំធេង ក្នុងបណ្តាប្រជាពលរដ្ឋខ្មែរនៅតាមព្រំប្រទល់ដែន » ។

សេចក្តីតែប៉ុណ្ណោះ យើងអាចយល់បានស្រេចហើយថាតើគ្រោះថ្នាក់ធំៗ និងនៅអនាគតជូនខ្មែរយើងគឺត្រង់ណា ? ខ្មែរយើងធ្លាប់បានយកបញ្ហានៃដំណើរឆ្លងមកទិសខាងលិចនៃជនជាតិយួននេះមកពោលរួចមកហើយ ចលនាមកទិសខាងលិចនេះ មិនត្រឹមតែមានលក្ខណៈនយោបាយ និងយោធាទេ គឺថែមទាំងជាលទ្ធផលយ៉ាងជាក់ស្តែង នៃការវិវដ្តនៃប្រវត្តិសាស្ត្រនៃដែនដីឥណ្ឌូចិនជាពិសេស ។ មុនពួកជនជាតិយួនទាំងនោះ បានធ្វើដំណើរមកពីទិសខាងត្បូងតាមជួរភ្នំអណ្ណាម (Les Cordillères annamitiques)

ហើយក្ដីដំណើរនេះ ដែលមានអាយុច្រើនសតវត្ស បាន លេបបាត់ទៅហើយ ខណៈបញ្ចប់ស្រុកតាំងពីដែនដីកម្ពុជាក្រោម ទៀតផង នៅដើមសតវត្សទី១៩ ( ក្នុងរវាងឆ្នាំ១៨៤០ ) ។ ហេតុយ៉ាងនេះហើយ បានជាព្រៃយទឹកខ្មៅ (Camau) ជា ដីមានស្រូវច្រើនបំផុតនៃឥណ្ឌូចិន ត្រូវជនជាតិយួនមកកាន់កាប់តាំង ទៅ ។

ជួនខ្លះបើថ្ងៃមុខ មានការកើតទីតាំងទៀត គឺដំណើរ ឆ្ពោះទៅទិសខាងលិច ហើយមកប៉ះនឹងប្រទេសកម្ពុជាយើង តែម្ដង ។ ខ្សែព្រឹត្តិការណ៍នេះ ដោយសារមានសង្គ្រាម នៅវៀតណាម តាំងពីឆ្នាំ១៩៤៥ រហូតមកដល់បច្ចុប្បន្ន កាលនេះ ជាកត្តាយ៉ាងធំ , បានមានរួចមកហើយ ហើយ ប្រាកដជានឹងមានការកើតឡើងៗទៅថ្ងៃមុខទៀត បើនៅតែ ការដែលនឹងតាក់តែងមានប្រសិទ្ធិភាពគ្រប់គ្រាន់ទេនោះ ។

លក្ខណៈផ្ទុយមួយទៀតនៃបញ្ហាសន្តិសុខនេះ គឺការ



ដែលបណ្ដាជនយួននេះ មានការបង្កើនចំនួនយ៉ាងលឿន ខ្លាំងប្រទេសជិតខាង មានការព្រួយបារម្ភជាចាំបាច់ ។ បើប្រសិនជាយើងយកស្ថិតិ ដែលគេបានធ្វើឡើង ដោយដៃ វិទ្យាសាស្ត្រមកពិនិត្យការណ៍នេះ រឹតតែច្បាស់ឃើញជាក់ស្ដែង ណាស់ទៅទៀត ៖ ការយោងកំណើនចំនួន ប្រជា ពលរដ្ឋយើង មានត្រឹម២,៥ ទៅ២,៦ ការយោងកំណើន ( le taux d'accroissement démographique ), ឯចំណែក យួន បើតាមអ្នកជំនាញការភាគរយនេះឡើងដល់ ទៅ៣ ភាគរយលើសយើងទៅទៀត ។ ម៉្យាងទៀតដល់ក្រោយ សង្គ្រាមនេះចប់ ការយោងនៃការបង្កើននេះ ប្រហាក់ប្រហែល នឹងកើនឡើងហួសពីភាគរយនេះទៅទៀត ។ ហេតុការណ៍ នេះ អាចមានផលវិបាកជាធ្ងន់ធ្ងរតែគេ មកលើប្រទេស ទាំងពីរប្រទេសជិតខាង ៖ ម៉្យាងទៀតក្នុងប្រទេសយួន ការ កើនឡើងនៃបណ្ដាជននេះ អាចនាំឲ្យមាន ជាបញ្ហាដីធ្លី (problèmes agraires) ដែលត្រូវឲ្យមានចំណាត់គ្រប់គ្រាន់ដើម្បី

ឆាប់ចិញ្ចឹមមនុស្សកាន់តែច្រើនឡើងៗ ។ គ្រាន់តែសព្វថ្ងៃនេះ ចំនួនប្រជាជន ខាងជើងនិងខាងត្បូងបញ្ចូលគ្នា ជាង ៦០ លាននាក់ទៅហើយ ហើយបញ្ហាដីធ្លីមានតែខ្វះៗឡើងមកហើយ , ចុះដល់៦០ឬ៧០ឆ្នាំទៀត ប្រជាជននេះត្រូវគុណពីរដង គឺ៧០ទៅ៨០លាននាក់ ! តើបញ្ហានេះនឹងមានទំហំធំដល់ណាទៅ ? លើកលែងតែអាចងាកសេដ្ឋកិច្ចឃ្លួនក្លាយទៅជាសេដ្ឋកិច្ចឧស្សាហកម្ម យ៉ាងល្អគួរណាស់ទាំងណាស់ទើបអាចដោះស្រាយបញ្ហានេះបាន , បើមិនយ៉ាងនេះទេ ជនជាតិយួនទាំងនេះនឹងត្រូវតែបញ្ចេញពីប្រទេសខ្លួន មកនៅលើដីជាតិឯទៀតដែលនៅទំនេរ ហើយដីដែលនៅទំនេរខាងនោះ គឺដែនដីខ្មែរយើងតែម្តង ។ ឯចំណែកដែនដីប្រទេសលាវជាដីភ្នំ ហើយបើតាមប្រវត្តិសាស្ត្រទៀត ជនជាតិវៀតណាមនេះ ជាមនុស្សដែលចូលចិត្តរស់នៅលើវាលទំនាប (l'homme de la plaine )គឺដែនដីសណ្ដនៃទន្លេមេគង្គតែម្តង ( le Delta ou la vallée du Mékong) ។ ម្យ៉ាងវិញទៀត ខ្មែរយើងក៏គួរ



ជាបើដល់ឆ្នាំ ២០០០ ប្រជាជនខ្មែរយើងកើនដល់ទៅ១៥លាននាក់ នេះបើតាមការស្មានតាមកម្រិតវិទ្យាសាស្ត្រ , ឯប្រទេសវៀតណាម នឹងកើនដល់ពី៩០ទៅ១០០លាននាក់ទៅហើយ ។ ម្យ៉ាងទៀតបើការស្រាយបញ្ហាប្រជាជននេះពុំបានស្រួលទេ នោះយើងបារម្ភខ្លាចក្រែងតែនឹងមានការបង្កើតគំនិតរណាមបញ្ញត្តិយួនដែលមានគំនិតជាតិនិយមហួសហេតុ ( l'ultra - nationalisme vietnamien ) ជាទ្រឹស្ដីកន្ត្រើតចិត្តជីវិនិយម ដើម្បីឲ្យប្រជាជាតិគេអាចរស់បាន( une nouvelle théorie de l'Espace Vital ) ។ ហើយបើទ្រឹស្ដីនេះកើតឡើងមែននោះ , ផលវិបាកនឹងមានលក្ខណៈធ្ងន់ធ្ងរក្រៃលែង មកលើអនាគតប្រទេសកម្ពុជាយើង ។

ម្យ៉ាងវិញទៀត ឯក្នុងប្រទេសយើងជនជាតិយួន ដែលរស់ក្នុងស្រុកខ្មែរយើងក៏កើនឡើងមិនចាញ់ដែរ ។ សព្វថ្ងៃនេះ អាណិកជនជាតិយួនទាំងនោះ មានចំនួនពី ៤៥០.០០០

ទៅ៥០០.០០០ នាក់ទៅហើយ[១] គឺជិតទៅ ៧ ភាគរយ នៃបណ្ដាជនខ្មែរយើងទាំងមូល ។ ហើយភាគរយនៃការកើនចំនួនប្រជាជនយួនទៅក្នុងស្រុកយើងទៀត គឺលើសភាគរយ នៃកំណើនប្រជាជនយើងផង ដូច្នេះហើយ ការកើននេះ ត្រូវតែលឿនទៅមុខជាថេរ ដោយបូកបញ្ចូលជាមួយផងនូវការលបលួចចូលមកទៀត លើដីខ្មែរយើង ដោយឥតច្បាប់ទម្លាប់នោះទៀត យើងបានសង្កេតឃើញជាទូទៅថា ជនជាតិយួន ដែលនៅស្រុកខ្មែរយើង ភាគច្រើនជាអ្នកក្រីក្រ ហើយភាពក្រីក្រនេះ បានបង្កើតឡើង នូវបញ្ហាធំផ្លូវសង្គមយ៉ាងធ្ងន់ធ្ងរ មានចោរកម្ម ឃាតកម្ម ភាពឥតការងារធ្វើ ល្បែងស៊ីសង ការលក់សម្ផស្សខ្លួនដើម្បីរស់ ។ល។ ហើយដោយហេតុថាខ្មែរនិងយួនរស់នៅជិតៗគ្នា ជួនកាលមានការទាក់ទងគ្នាទៅវិញទៅមកផងក៏មាន ផលវិបាកនេះ គឺវាត្រូវធ្លាក់មកលើសង្គមខ្មែរយើង ឥតពេលប្រែកក៏ពុំខានឡើយ ។ នេះជាបញ្ហា

---

(១) ចុង ១៥ មិនា ១៩៧០ ។



ផ្លូវសង្គមវិទ្យា ( un problème sociologique ) គប្បីតែយើងចាប់អារម្មណ៍ដើម្បីឲ្យសង្គមខ្មែររក្សាឲ្យបានល្អគង់ភាពជាសុខ ។

ព្រឹត្តិការណ៍មួយទៀត ដែលយើងគួរចាប់អារម្មណ៍ ជាពិសេស ការបង្កើនចំនួនកាន់តែច្រើន នៃការកើតជនបរទេសយួន លើផែនដីយើង ហើយបើយើងបូកបញ្ចូលទាំងការកើតជនបរទេសចិន មកទៀតផង និង គាបមានផលវិបាក មួយទៀតគួរឲ្យព្រួយបារម្ភ ក្នុងអនាគតកាល ។ ព្រោះតែសព្វថ្ងៃនេះ ជនបរទេសទាំងពីរយ៉ាងនេះ មានចំនួនជិត មួយលាននាក់ទៅហើយ ក្នុងចំនួនប្រជាជនយើងមិនលើស ជាង ៧ លាននាក់ ។ បើយើងនិយាយឲ្យកាន់តែច្បាស់ទៅទៀត គឺក្នុងខ្មែរទាំងអស់ ៧ នាក់ មានបរទេសចិន–យួន ១ នាក់ ។ ហេតុការណ៍នេះ គាប និង បណ្ដាលឲ្យមានឡើងជា បញ្ហាពូជសាសន៍ (un problème racial) ហើយដែល និង មានលក្ខណៈជាបញ្ហាផ្លូវសង្គមទៀតផង ។ នៅប្រទេសម៉ាឡាយស៊ី ។ នេះ

មានផ្ទុះរឿងសាសន៍នេះ បណ្ដាលឲ្យមានការរើករើ ខ្លួនគេ ខ្លះស្ដែកកាកទាំងផ្លូវនយោបាយ ហើយសព្វថ្ងៃនេះក្ដី បញ្ហានេះក៏មិនទាន់ចប់សព្វគ្រប់នៅឡើយដែរ ។ ការណ៍កើតមានបែបទេសជាតិយួន នៅស្រុកយើងសព្វថ្ងៃនេះ ក៏មែននៅស្ងៀមស្ងាត់ចុះគ្នាឡើយ គេមានអង្គការសម្ងាត់គ្រប់បែបយ៉ាង ទាំងផ្លូវសាសនា ក៏ដូចជាទាំងផ្លូវនយោបាយ ។ រឿងអស់នេះនរណាក៏ដឹងគ្រប់ ៗ គ្នាហើយដែរ ។

សព្វថ្ងៃនេះ គេឃើញពួកគេ នៅហាក់ដូចជាស្ងៀមស្ងាត់ ពីព្រោះពេលនេះ យួនកំពុង ជាប់ធ្វើសង្គ្រាម នៅប្រទេសវៀតណាម ហើយជា ប្រយោជន៍របស់គេពីណាស់ ដែលត្រូវឲ្យគេមានការទាក់ទងយ៉ាងប្រពៃ ជាមួយនឹងជាតិខ្មែរយើង ។ ចុះដល់ពេលចប់សង្គ្រាមទៅ ប្រទេសគេរួបរួមគ្នាវិញឬទេ ? បើមិនរួបរួមទាំងផ្លូវនយោបាយក៏ទាំងផ្លូវសេដ្ឋកិច្ច ទៀតមិដែរ ហើយប្រទេសគេ នឹងក្លាយទៅជាមហាអំណាចអាស៊ីមួយ ដែលពិភពលោក បានទាយទុកហើយនោះ ជន



ជាតិវៀតណាមនៅស្រុកខ្មែរ ច្បាស់ជានឹងមានសម្បជញ្ញៈចំពោះកម្លាំងរបស់ខ្លួន មិនខានឡើយ ( La prise de conscience de leur force en tant que minorité ethniquement et politiquement dominante) ហើយ នឹង មានការទាមទារផ្សេង ៗ ទាំងផ្លូវសង្គម ឬផ្លូវនយោបាយមិនខានឡើយ ។

នេះជាគ្រោះថ្នាក់មួយធំធេង ពីព្រោះនឹងអាចបណ្ដាលឲ្យការល្អក់ ក្នុងការទាក់ទងខ្មែរ - យួន នៅអនាគតកាលមិនចេះចប់ មិនចេះហើយ ។ បានជាយើងហ៊ានអះអាងយ៉ាងនេះ មិនមែនដោយយើងមានគំនិត ស្អប់ជនជាតិយួនពីដូនតា ( une haine héréditaire ) នាំមកទេ គឺមកពីការដែលយើងធ្លាប់ពិភាក ក្នុងបញ្ហាខ្មែរ- យួននេះកន្លង ។ នេះជាការពិតមួយ ដែលមានលក្ខណៈជាការចាំបាច់ ព្រោះប្រវត្តិសាស្ត្រមនុស្សជាតិ បានប្រទះប្រហែលនេះច្រើនណាស់មកហើយ ក្នុងសតវត្សទី ២០ នេះកន្លង ។

## ឯណាការដោះស្រាយ ?

ការដោះស្រាយដែលប្រពៃ មិនមែនការប្រើ«ធម៌ក្ដៅ» នោះទេ ព្រោះថាបើប្រើធម៌ក្ដៅ នឹង បណ្ដាលឲ្យមានប្រតិកម្មលក្ខណៈ ជា « ធម៌ក្ដៅ » តបមកវិញ មិនចប់មិនហើយ និងធ្វើឲ្យជម្លោះ រវាងខ្មែរ និងយួន កាន់តែមានទំហំធំឡើងៗ អស់មានស្ថេរភាពនយោបាយ ក្នុងតំបន់ជាប្រាកដ ។ យើងនិយាយ « ធម៌ក្ដៅ » នេះ គឺចង់និយាយដល់ការបង្ខំឲ្យអាណិកជនយួនទាំងនេះ វិលត្រឡប់ទៅស្រុកកំណើតវិញ (le rapatriement forcé) . . . វិធានការនេះ បណ្ដាលឲ្យមានផលវិបាក អាក្រក់ទៅលើសេដ្ឋកិច្ចជាតិ ៖ យើងនឹងបាត់បង់នូវក្រុមខណ្ឌ សេដ្ឋកិច្ច និង បច្ចេកទេសច្រើន , ដែលទាំងផ្លូវក្នុងប្រទេសយើង យ៉ាងសំខាន់ទៀត , ដែលជាការចាំបាច់ចំពោះអនាគត ការលូតលាស់ឧស្សាហកម្ម និងសេដ្ឋកិច្ចប្រទេសកម្ពុជាយើង ។ ហើយនោះបើការបង្ខំឲ្យវិលទៅស្រុកកំណើតវិញ អាចធ្វើកើត ក៏នឹងបណ្ដាលឲ្យ



មានបញ្ហាធំ ដែលនឹងហួសសមត្ថភាពរបស់យើងទៀតផង ។ ដូច្នេះ វិធានការ ដែលយើងអាចគិតទៅបាន ដោយមិនបង្កើតជាបញ្ហាធ្ងន់ធ្ងរតទៅទេ គឺការត្រួតត្រាឲ្យបាន ដិតដល់ដល់សកម្មភាពគ្រប់បែបយ៉ាង ទាំងផ្លូវ សាសនាក្ដី ទាំង ផ្លូវសង្គម ឬ នយោបាយ ក្ដី ដែលអាណិកជនជាតិយួនទាំងអស់មានក្នុងប្រទេសយើង ដើម្បីអាចឲ្យយើងរំងាប់បាន (neutra-liser ) នូវគ្រប់បំណងអាក្រក់ទាំងឡាយ ដែលនឹងអាចចាប់ផ្ទុះផ្ដើមឡើង ។

ហើយសំខាន់ជាងនេះទៅទៀត គឺការបិទព្រំដែនឲ្យបានជិតជុំ កុំឲ្យមានការទុកចិត្ត ឈប់ឲ្យមានការលួចនាំចូលប្រទេសមកតាមវិធីពាណិជ្ជកម្ម ឬ ដោយការស៊ីក្រឡប់ខុសសម្បជញ្ញៈ ។ យើងត្រូវយល់ថា បើមានការលបលួចចូលមកម្ដងមួយកាល (Temporaire) នោះមិនមែនជាគ្រោះថ្នាក់ធ្ងន់ធ្ងរប៉ុន្មានទេ គ្រោះថ្នាក់ដែលធំ គឺការ មកតាំងទីលំនៅជានិច្ចកាល (Implantations permanentes) ដោយមានការ

សង់ផ្ទះសម្បែង ការប្រកបរកស៊ីកម្ម ឬ មុខរបរផ្សេងៗ ទៀត ព្រោះជនប្រភេទនេះ ដែលមាន « ចូស » ជាប់នឹងដីយើងហើយ និងមានគ្រួសារ មិត្តភក្តិ មិនងាយវិលត្រឡប់ទៅវិញងាយ ៗ ឡើយ ។ ហើយបើយ៉ាងនេះទៅ ទល់តែយើង នឹងត្រូវបរទេសយួនមកតាំងនៅកកកុញ រួចហើយ ក៏បណ្តាលឲ្យមានជម្លោះ រករឿងហេតុជាមួយ និងបង្ខូចខ្មែរយើង បង្កើតឲ្យមានការពិបាករស់នៅ ឯខ្មែរយើងជាជាតិស្លូតត្រង់ មិនជាអ្នករករឿងហេតុគេ ក៏ត្រូវបោះបង់ចោលទីនោះ រត់មកនៅឆ្ងាយ ៗ ទៀត ។ល។ នេះគ្រាន់ជាការដណ្តើមទឹកដី ដោយវិធីស្ងៀមស្ងាត់ ដែលយើងគួរតាមគាមេលណ៍ឲ្យបានជាក់ច្បាស់ ។

ដូចយើងបានធ្វើការវែកញែករួចមកហើយ សេចក្តីសង្ឃឹមរបស់យើងទាំងស្រុង ស្ថិតនៅលើរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលនឹងមានសប្បជញ្ញៈច្បាស់លាស់ ចំពោះគ្រោះថ្នាក់ ដ៏ធំធេងនេះ ដល់មាតុប្រទេសកម្ពុជារបស់យើង ។ បើបញ្ហាទាំងនេះ



មិនបានទទួលការដោះស្រាយ ត្រូវជាទីគាប់ចិត្តទេ អនាគតរបស់យើងនឹងមានពពកខ្មៅងងឹតគ្របបាំងមិនខានឡើយ ក្នុងក្របខណ្ឌនៃការវិវត្តនយោបាយទូទៅ ក្នុងភូមិភាគឥណ្ឌូចិន ដ៏រំជើបរំជួលនេះ ។

ស. ម៉ាលី

ភ្នំពេញ ថ្ងៃទី២៣ ធ្នូ ១៩៦៩

# ឥណ្ឌូចិន
# ក្នុងឆ្នាំ២០០០...

**សការវ៉ា** Sacrava news

No 84

1/ 11 / 2003




គំនិត ឬទ្រឹស្ដីដែលថែរក្សាបណ្ដាជន (la population) និងការរក្សានូវបណ្ដាជននេះមាន នាទីដ៏សំខាន់ មួយនៅក្នុងវិស័យ នយោបាយជាតិ និងអន្តរជាតិនេះម៉ែនទែនជាគំនិត ឬទ្រឹស្ដីដ៏ថ្លៃថ្នូរ ៗ ជាការពិតណាស់ហើយដែលគេពោលថា "មនុស្ស" ជាមូលដ្ឋាននៃសារវត្ថុនៃគ្រប់របបគ្រប់គ្រប់នយោបាយនៃប្រជាជាតិ ឬសង្គមមនុស្សទាំងឡាយ ។ ហេតុនេះទើបបានជាចំនួនមនុស្សពោលគឺបណ្ដាជនក្នុងប្រទេសនិមួយៗ ឬក្នុងតំបន់ភូមិភាគនិមួយៗ, ត្រូវតែមានអត្ថិភាពជាការចាំបាច់លើស្ថានភាព ឬកិច្ចដឹកនាំនយោបាយ ក្នុងប្រទេសឬក្នុងភូមិភាគដែលប្រមូលផ្ដុំប្រទេសទាំងនោះ ។ ដូច្នេះបើយោលទៅតាមទ្រឹស្ដីនេះ ចំនួនបណ្ដាជននិងការដឹកនាំនយោបាយពុំអាចត្រូវគេកាត់ផ្ដាច់ចេញពីគ្នាបានឡើយ ។

# បណ្ដាជនច្រើនហួសមាឌ

## La surpopulation

ដោយហេតុនោះតាមទ្រឹស្ដីខាងលើនេះ ប្រវត្តិវិទូនិងសង្គមវិទូ (Sociologue) ភាគច្រើនបានពន្យល់អំពីបុព្វហេតុនៃសង្គ្រាមរវាងជាតិនិងជាតិ (Causes des guerres) និង ចលនាបដិវត្តន៍ (mouvements révolutionnaires) ដែលបានចាប់កំណើតឡើងក្នុងប្រទេសឬក្រុមភាគីមួយ ៗ នៃពិភពលោក ដោយពឹងផ្អែកទៅលើស្ថានភាពនិងចលនានៃការវិវត្តន៍នៃបណ្ដាជននេះតែម្ដង ។ ប្រវត្តិសាស្ត្ររបស់មនុស្សជាតិហាក់ដូចជាបានកត់សំគាល់នូវព្រឹត្តិការណ៍ ជាច្រើនរួចមកហើយ ដែលនាំឲ្យយើងយកមកបញ្ជាក់បកស្រាយពន្យល់នូវទ្រឹស្ដីខាងលើនេះ ៖ ក្នុងរវាងឆ្នាំ ១៩៣០, ប្រទេសអាល្លឺម៉ាញសម័យហ៊ីត្លែរ នៅអឺរ៉ុប, និងប្រទេសជប៉ុនសម័យយោធានិយមនៅអាស៊ី, បានធ្វើនយោបាយយោធានិយមជំរុញទៅ បង្កបង្កើតឲ្យមានសង្គ្រាមក្នុងពិភពលោក ក្រោម



តាំងបានផ្សព្វផ្សាយនូវសេចក្ដីក្រៀមក្រំ និងការខ្ចាត់ផ្លាស់រយៈជាច្រើនឆ្នាំមកលើមនុស្សជាតិ ។

ប្រទេសទាំងពីរនេះ ក្នុងសម័យនោះ សុទ្ធសឹងជាប្រទេសដែលមានបណ្ដាជនច្រើនហួសមាឌហួសសមត្ថភាពនៃការដោះស្រាយសមញ្ញនៃប្រទេសទាំងពីរ ៖ ឯនយោបាយគេច្រើកទឹកដីនិយមនិងសង្គ្រាមឈ្លានពានទៅលើប្រជាជាតិជិតខាង ដែលប្រទេសទាំងនេះបានបង្កបង្កើតឡើង គឺពិតជានៅក្នុងគោលបំណងនយោបាយមួយយ៉ាងច្បាស់លាស់ គឺវាយដណ្ដើមយកទឹកដីប្រទេសមកធ្វើជារបស់ខ្លួន ដើម្បីជាមធ្យោបាយធានាឲ្យប្រទេសខ្លួនមានផែនដីគ្រប់គ្រាន់ (Espace vital) សំរាប់ចិញ្ចឹមបណ្ដាជនរបស់ប្រទេសគេ ដែលកាន់តែកើនចំនួនច្រើនឡើង ៗ ជាលំដាប់រៀងរាល់ឆ្នាំ ។ គឺក្នុងគោលបំណងនេះហើយ ដែលជំរុញឡើងប្រទេស ជប៉ុន បានឈ្លានពានយកដណ្ដើមយកផែនដី កូរ៉េ (Corée) និង ម៉ាន់ជូរី (Mandchourie) នាប្រទេសចិនផែកខាងជើង, ក្រោមតាំងពីកកំហែងដល់តាណា